# សាលាបឋមសិក្សា អ៊ីលីហ្សា B. ឃើគប្រាយ

**1501 South Seventh Street**
**Philadelphia, PA 19147**
**215-952-6214**

ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៤

**ជូនចំពោះ មាតាបិតា/អាណាព្យាបាលរបស់ សិស្សានុសិស្សថ្នាក់ទី ៦៖**

ច្បាប់រដ្ឋផិនស៊ីលវេញ៉ា តម្រូវឲ្យសិស្សានុសិស្សទាំងអស់មានការ ***ពិនិត្យសុខភាព និង ពិនិត្យធ្មេញ ឲ្យបានគ្រប់ចំនួន នៅពេលចូលរៀនថ្នាក់ទី៦។*** ជាបន្ថែមទៀត គេតម្រូវឲ្យសិស្សទាំងអស់មានឯកសារចាក់ថ្នាំបង្ការរោគគ្រប់ចំនួន នៅក្នុងសំណុំឯកសាររបស់ពួកគេ។ គិលានុបដ្ឋាកសាលារបស់យើងបានធ្វើការ ពិនិត្យ និង វាយតម្លៃ សំណុំឯកសារនៃការពិនិត្យសុខភាព និងការចាក់ថ្នាំបង្ការរោគ ទាំងអស់របស់សិស្ស យ៉ាងហ្មត់ចត់។ លទ្ធផលនៃការពិនិត្យនេះ គិលានុបដ្ឋាកសាលារបស់យើងបានសម្រេចពីឯកសារដែលយើងត្រូវការសម្រាប់កូនរបស់លោកអ្នក ដើម្បីឲ្យត្រូវតាម ច្បាប់ និង តម្រូវការ របស់រដ្ឋផិនស៊ីលវេញ៉ា។

**មកទល់ថ្ងៃនេះ យើងខ្ញុំមិនទាន់បានទទួល ការពិនិត្យសុខភាព និង ការចាក់ថ្នាំបង្ការរោគ ដែលមាននៅក្នុងបញ្ជីខាងក្រោមនេះនៅឡើយ។** សូមជ្រាបថា ដើម្បីអាចត្រឡប់មករៀនវិញនៅ ***ថ្ងៃច័ន្ទ ទី២៩ ខែកញ្ញា ឆ្នាំ២០១៤*** អ្នកត្រូវ**បំពេញ និង ប្រគល់** ការពិនិត្យ**សុខភាព** និងការចាក់ថ្នាំបង្ការរោគ ដែលគេបានស្នើសុំ**សម្រាប់កូនរបស់លោកអ្នកទាំងអស់** ឲ្យទៅគិលានុបដ្ឋាកសាលា។

**ចាប់ផ្តើមមានប្រសិទ្ធិភា**ពនៅ ***ថ្ងៃច័ន្ទ ទី២៩ ខែកញ្ញា ឆ្នាំ២០១៤*** គេមិនអនុញ្ញាតឲ្យកូនលោកអ្នកត្រឡប់មករៀនវិញទេ បើគ្មានតម្រូវការដូចខាងក្រោមនេះ ឬ **បើគ្មានការណាត់ជួបជាមួយ វេជ្ជបណ្ឌិត និង ពេទ្យធ្មេញ របស់កូនលោកអ្នក**។

_*_ ការពិនិត្យរាងកាយ/**Physical Examination**
_*_ ការពិនិត្យធ្មេញ/**Dental Examination**
_*_ **ប្រវត្តិសុខភាពរបស់សិស្ស** (ពណ៌ផ្កាឈូក) **/Student Medical History (Pink)**
_*_ **ព័ត៌មានសម្រាប់ទាក់ទងពេលមានអាសន្ន** (ពណ៌ដាំដែក) **/Student Emergency Information Form (Tan)**
_*_ **ឯកសារចាក់ថ្នាំបង្ការរោគ/Immunization Record**
_*_ **តេតាណុស ខាន់ស្លាក់ និង ក្អកមាន់ /Tetanus, Diphtheria, & Acellular, Pertussis (Tdap)**
_*_ **រោគរលាកស្រោមខួរ/Meningoccoccal (Menactra)**
_*_ **កញ្ជ្រឹល សាលាទែន កញ្ជ្រឹលស្រាល លើកទី១/Measles, Mumps, Rubella #1 (MMR)**
_*_ **កញ្ជ្រឹល សាលាទែន កញ្ជ្រឹលស្រាល លើកទី២/Measles, Mumps, Rubella #2 (MMR)**
_*_ **ថ្នាំបង្ការរោគអុតតូច លើកទី១ ឬរោគអុតស្វាយ/Varicella Vaccine #1 or Chicken Pox Disease**
_*_ **ថ្នាំបង្ការរោគអុតតូច លើកទី២ ឬរោគអុតស្វាយ/Varicella Vaccine #2 or Chicken Pox Disease**

ដោយសេចក្តីស្មោះស្ម័គ្រ

Dr. Magness
នាយកសាលា